ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

TELECOMMUNICATION REGULATOR OF CAMBODIA
TRC

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :...១៦០៦.........ន.ទ.ក.

# សេចក្តីណែនាំ
# ស្តីពី
# វិធានការពង្រឹងការអនុវត្តច្បាប់ស្តីពីទូរគមនាគមន៍

ដោយពិនិត្យឃើញថា កន្លងមកប្រតិបត្តិករទូរគមនាគមន៍មួយចំនួនពុំទាន់បានអនុវត្តតាមច្បាប់ស្តីពីទូរគមនាគមន៍ បទប្បញ្ញត្តិ និងលក្ខខណ្ឌនៃអាជ្ញាបណ្ណពាក់ព័ន្ធនឹងការធ្វើប្រតិបត្តិការបណ្តាញ និងសេវាទូរគមនាគមន៍បានល្អនៅឡើយ ដូច្នេះ និយ័តករទូរគមនាគមន៍កម្ពុជា (**ន.ទ.ក.**) សូមធ្វើការណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ដូចខាងក្រោម៖

**១**) ធ្វើស្វ័យប្រកាស និងបង់កម្រៃអាជ្ញាបណ្ណ (ចំណូលបែងចែក) វិភាគទានមូលនិធិកាតព្វកិច្ចសេវាសកល (២%) វិភាគទានមូលនិធិការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍ (១%) និងចំណូលពាក់ព័ន្ធដទៃទៀត ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) ឱ្យបានទាន់ពេលវេលា ស្របតាមការកំណត់នៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍, អនុក្រឹត្យលេខ១១១ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់យន្តការសម្រាប់អនុវត្តកម្មវិធីកាតព្វកិច្ចសេវាសកលវិស័យទូរគមនាគមន៍, អនុក្រឹត្យលេខ១១២ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការកំណត់យន្តការសម្រាប់គ្រប់គ្រងផែនការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន និងបទប្បញ្ញត្តិជាធរមាន។ ដោយឡែក ប្រតិបត្តិករផ្តល់សេវាទូរគមនាគមន៍ ត្រូវធ្វើស្វ័យប្រកាសនិងបង់កម្រៃនិយ័តករ និង/ឬផ្តល់របាយការណ៍ស្ថិតិសេវាទូរគមនាគមន៍ជូន **ន.ទ.ក.** ជាប្រចាំខែ និងមិនត្រូវឱ្យហួសថ្ងៃទី១០ នៃខែបន្ទាប់នីមួយៗជាដាច់ខាត។

**២**) ប្រតិបត្តិករទូរគមនាគមន៍ ដែលមិនទាន់បានបំពេញកាតព្វកិច្ចតភ្ជាប់ និងផ្តល់ទិន្នន័យរបស់ខ្លួនមកមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យា (DMC) ស្របតាមមាត្រា៦ នៃច្បាប់ស្តីពីទូរគមនាគមន៍, អនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យានៃ **ក.ប.ទ.** និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ត្រូវធ្វើការតភ្ជាប់ និងផ្តល់ទិន្នន័យជាបន្ទាន់ និងឱ្យបានរួចរាល់យ៉ាងយូរត្រឹមចុងខែធ្នូ ឆ្នាំ២០២០ ជាកំហិត។

**៣**) ប្រតិបត្តិករទូរគមនាគមន៍ទាំងឡាយណាដែលបានឬកំពុងលួចបន្លំបង្វែរចរន្តត្រាហ្វិកសេវា និងទំហំនៃចំណូលដែលជាហេតុធ្វើឱ្យមានការលម្អៀងទិន្នន័យដែលខ្លួនបានធ្វើស្វ័យប្រកាសបង់ចំណូលបែងចែក និងកម្រៃនិយ័តករជាមួយទិន្នន័យដែលបានទទួលដោយមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យសេវាទូរគមនាគមន៍និងព័ត៌មានវិទ្យា ដែលជាហេតុធ្វើឱ្យបាត់បង់ចំណូលជាតិពីវិស័យ ត្រូវចូលខ្លួនទៅធ្វើការដោះស្រាយជាមួយ **ក.ប.ទ.** ឱ្យបានសមស្រប។ ក្នុងករណីប្រតិបត្តិករទូរគមនាគមន៍ មិនអើពើធ្វើការកែតម្រូវលើបញ្ហានេះទេ ប្រតិបត្តិករទូរគមនាគមន៍នឹងប្រឈមមុខនឹងការចោទប្រកាន់ដូចមានចែងក្នុងមាត្រា៨៥ មាត្រា៨៦ មាត្រា៨៧ និងមាត្រា៨៨ នៃច្បាប់ស្តីពីទូរគមនាគមន៍។

**៤**) បញ្ឈប់ជាបន្ទាន់ចំពោះការលក់និងចែកចាយស៊ីមកាតដោយមិនយកឯកសារបញ្ជាក់អត្តសញ្ញាណរបស់អ្នកជួលជាវសេវា ដែលជាហេតុនាំឱ្យប៉ះពាល់ដល់កិច្ចការសន្តិសុខសាធារណៈ និងសន្តិសុខជាតិ ហើយត្រូវអនុវត្តឱ្យស្របតាមសារាចរលេខ០០១ ស.រ មផ-បទ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ និង **ក.ប.ទ.** និងការណែនាំនាពេលកន្លងមករបស់ **ន.ទ.ក.** ឱ្យបានដាច់ខាត។

**៥**) បញ្ឈប់ជាបន្ទាន់រាល់ការប្រកួតប្រជែងមិនស្របច្បាប់ និងការផ្តល់សេវាទូរគមនាគមន៍ដោយពុំមានគុណភាព ឬពុំមានភាពសុចរិតតាមរយៈការបង្កើតឱ្យមានកញ្ចប់សេវាច្រើនប្រភេទដែលធ្វើឱ្យអ្នកប្រើប្រាស់មានការភាន់ច្រឡំ ហើយហាម

ឃាត់ដាច់ខាតរាល់ការកាត់ផ្ដាច់បណ្ដាញ ឬរាំងខ្ទប់ចរន្តត្រាហ្វិករបស់បណ្ដាប្រតិបត្តិករទូរគមនាគមន៍នានា។ រាល់ការផ្សព្វផ្សាយជម្រុញការលក់ (Promotion) ឬ កាត់ផ្ដាច់បណ្ដាញរបស់ប្រតិបត្តិករទូរគមនាគមន៍ណាមួយ ត្រូវសុំការអនុញ្ញាតជាមុនពី **ន.ទ.ក.** ស្របតាមបទប្បញ្ញត្តិជាធរមាន។

**៦**) រាល់ការផ្លាស់ប្ដូរលក្ខន្តិកៈក្រុមហ៊ុន អាសយដ្ឋានក្រុមហ៊ុន ម្ចាស់ភាគហ៊ុន ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ការទិញយកក្រុមហ៊ុន ឬភាគហ៊ុន សន្តតិកម្ម ការដាក់ប្រាតិភោគនូវសិទ្ធិដែលកំណត់ក្នុងលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់ស្របតាមសេចក្ដីណែនាំលេខ ១២៥២ ន.ទ.ក. ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ របស់ **ន.ទ.ក.** ។

**៧**) រាល់ពេលធ្វើកិច្ចព្រមព្រៀងតភ្ជាប់ ឬជួលជាវបណ្ដាញ ឬសេវា ប្រតិបត្តិករទូរគមនាគមន៍ត្រូវស្នើសុំការពិនិត្យ និងសម្រេចពី **ន.ទ.ក.** ស្របតាមមាត្រា ៣១ នៃច្បាប់ស្ដីពីទូរគមនាគមន៍ និងប្រការ៥ នៃប្រកាសលេខ២០៦ បទ.ប្រក. ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៩។ បន្ថែមលើនេះ ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្ដល់រាល់កិច្ចព្រមព្រៀងតភ្ជាប់ ឬជួលជាវបណ្ដាញ ឬសេវា និងកិច្ចព្រមព្រៀងគោល ដែលបានធ្វើកន្លងមក ជូន **ន.ទ.ក.** ភ្លាមៗបន្ទាប់ពីកាលបរិច្ឆេទនៃសេចក្ដីណែនាំនេះ ដើម្បី **ន.ទ.ក.** រៀបចំជាបញ្ជីស្របតាមមាត្រា ៣៣ នៃច្បាប់ស្ដីពីទូរគមនាគមន៍។

**៨**) ត្រូវបញ្ឈប់ និងរុះរើទម្លាក់ជាបន្ទាន់នូវការលួចបង្កើត ដំឡើង ប្រើប្រាស់ កែប្រែហេដ្ឋារចនាសម្ព័ន្ធបណ្ដាញទូរគមនាគមន៍ និងគ្រឿងសម្ភារៈបរិក្ខារ ដើម្បីបញ្ជូនទទួល ឬពង្រីកសេវាទូរគមនាគមន៍ពុំស្របច្បាប់នៅគ្រប់រាជធានី/ខេត្ត និងនៅតាមបណ្ដោយព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។ ចំពោះប្រតិបត្តិករទូរគមនាគមន៍ដែលបានទទួលអាជ្ញាបណ្ណ ឬការអនុញ្ញាតឱ្យតភ្ជាប់បណ្ដាញឆ្លងកាត់បន្ទាត់ព្រំដែន ត្រូវបំពាក់ស្លាកសញ្ញាសម្គាល់អត្តសញ្ញាណ និងត្រូវផ្ដល់ព័ត៌មានលម្អិតនៃទីតាំង ប្លង់ស្ថាបនា និងទិន្នន័យបច្ចេកទេសពាក់ព័ន្ធនឹងបណ្ដាញរបស់ខ្លួនជូន **ន.ទ.ក.** និងមន្ទីរ ប.ទ. នៃ **ក.ប.ទ.**។ រាល់ការស្ថាបនាបណ្ដាញនីមួយៗឆ្លងកាត់បន្ទាត់ព្រំដែន ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ទ.ក.** ។

**៩**) ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវផ្ដល់របាយការណ៍ថ្លៃដើម របាយការណ៍គុណភាពនៃសេវា និងផែនការមេក្នុងការពង្រីកសេវាគ្របដណ្ដប់និងគុណភាពសេវាមក **ន.ទ.ក.** តាមការកំណត់ដូចខាងក្រោម៖

- របាយការណ៍ប្រចាំឆមាសទី១ ត្រូវឱ្យបានមុនថ្ងៃទី១៥ ខែកក្កដា
- របាយការណ៍ប្រចាំឆមាសទី២ ត្រូវឱ្យបានមុនថ្ងៃទី១៥ ខែមករា។

ក្នុងករណី ប្រតិបត្តិករទូរគមនាគមន៍ណាមួយមិនអនុវត្តតាមសេចក្ដីណែនាំនេះ ប្រតិបត្តិករទូរគមនាគមន៍នោះនឹងប្រឈមចំពោះមុខច្បាប់ ។

ទទួលបានសេចក្ដីណែនាំនេះ ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះប្រកបដោយប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕ BR. 

ថ្ងៃ ពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០

**ប្រធាន**

**ម៉ុង ចរិយា**

**ចម្លងជូន៖**

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
  "ដើម្បីជូនជ្រាប"
- ប្រតិបត្តិករទូរគមនាគមន៍
- ឯកឧត្តមសមាជិក នាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ន.ទ.ក.
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ